**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២១៤:រ៉ែ:អ្នជា.សភណ

# សេចក្តីណែនាំ
# ស្តីពីការពង្រឹងការគ្រប់គ្រង និងប្រមូលសួយសារធនធានរ៉ែសំណង់ តាមបណ្តារាជធានី-ខេត្ត

ក្នុងគោលបំណងពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលសួយសារធនធានរ៉ែសំណង់គ្រប់ប្រភេទឲ្យប្រព្រឹត្តទៅដោយត្រឹមត្រូវ និងមានប្រសិទ្ធភាពស្របតាមប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល និងប្រកាសលេខ ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែ ដោយសម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់ ក្រសួងរ៉ែ និងថាមពល សូមធ្វើការណែនាំដល់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ដូចខាងក្រោម៖

<u>១) ការប្រមូលចំណូលសួយសារ</u>

១-១ មន្ទីររ៉ែ និងថាមពលត្រូវចាត់ចែងប្រមូលចំណូលសួយសាររ៉ែ ដែលអាជីវករ ក្រុមហ៊ុន មិនទាន់បានបង់ជូនរដ្ឋពីមុនរហូតមកដល់ខែមីនាឆ្នាំ២០១៥ តាមអត្រាសួយសារដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ ០០៦ ប្រក.សហវ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការកំណត់ថ្លៃវត្ថុធាតុដើមថ្មសម្ភារសំណង់ ឲ្យបានចប់សព្វគ្រប់នៅមុនដំណាច់ខែមិថុនា ឆ្នាំ២០១៥។ អត្រាសួយសារថ្មីដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ត្រូវចាប់អនុវត្តពីត្រីមាសទី២ ឆ្នាំ២០១៥ តទៅ។

១-២ ក្នុងដំណាក់កាលដំបូងនៃការអនុវត្តនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែសំណង់ អាជីវករ ក្រុមហ៊ុនត្រូវបង់សួយសារតាមផលិតកម្មជាក់ស្តែងរបស់ខ្លួនក្នុងត្រីមាសទី២ ឆ្នាំ២០១៥ និងត្រូវបង់ប្រាក់រំដោះថ្លៃសួយសារសម្រាប់ត្រីមាសទី៣ ឲ្យបានមុនថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥។ អាជីវករ ក្រុមហ៊ុន ត្រូវធ្វើការប្រកាសសួយសាររ៉ែសំណង់របស់ខ្លួនក្នុងលិខិតប្រកាសសួយសារធនធានរ៉ែសម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់ (ឧបសម្ព័ន្ធទី១) នៅតាមមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ដែលការធ្វើអាជីវកម្មរបស់ខ្លួនស្ថិតនៅ។ មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវចេញលិខិតបញ្ជាក់បង់ប្រាក់ចំណូលសួយសារលើតម្លៃធនធានរ៉ែជូនអាជីវករ ក្រុមហ៊ុន តាមគំរូដែលកំណត់ដោយក្រសួងរ៉ែ និងថាមពល (ឧបសម្ព័ន្ធទី២)។

១-៣ នៅក្នុងករណីអាជីវករ ក្រុមហ៊ុនមានបំណងធ្វើការប្រកាសសួយសាររ៉ែសំណាង់របស់ខ្លួននៅអគ្គនាយកដ្ឋានធនធានរ៉ែវិញនោះ ត្រូវតម្រូវឲ្យអាជីវករក្រុមហ៊ុន ធ្វើការជូនដំណឹងទៅមន្ទីររ៉ែ និងថាមពល រាជធានី ខេត្ត ដែលការធ្វើអាជីវកម្មរបស់ខ្លួនស្ថិតនៅ អំពីការស្នើសុំប្តូរទីកន្លែងធ្វើការប្រកាសសួយសារនោះ។ អគ្គនាយកដ្ឋានធនធានរ៉ែ នឹងចេញនូវលិខិតបញ្ជាក់បង់ប្រាក់ចំណូលសួយសារលើតម្លៃធនធានរ៉ែ ជូនអាជីវករ ក្រុមហ៊ុន ហើយចម្លងជូនមន្ទីររ៉ែ និងថាមពលវិញ។

១-៤ មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវពិនិត្យតាមដាន លើកាតព្វកិច្ចបង់ប្រាក់របស់អាជីវករ ក្រុមហ៊ុនជាប្រចាំ ហើយត្រូវមានវិធានការជាបន្ទាន់ ប្រសិនបើអាជីវករ ក្រុមហ៊ុន នៅមិនទាន់បង់សួយសាររ៉ែ ក្រោយថ្ងៃផុតកំណត់បង់ប្រាក់ដែលមានចែងក្នុងលិខិតបញ្ជាក់បង់ប្រាក់ចំណូលសួយសារលើតម្លៃធនធានរ៉ែ។

២) <u>ការធ្វើអាជីវកម្មជីកដីចល័ត</u>

កន្លងមក ក្រសួងបានសង្កេតឃើញមានការធ្វើអាជីវកម្មជីកដីចល័ត ដែលមានរូបភាពជាការធ្វើអាជីវកម្មលក់អាចម៍ដីយកទៅចាក់បំពេញនៅទីតាំងផ្សេងទៀត ដែលជាហេតុធ្វើឲ្យបាត់បង់នូវចំណូលសួយសារជាច្រើន។ ចំពោះការធ្វើអាជីវកម្មជីកដីចល័តនេះ មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវណែនាំដល់អាជីវករឲ្យធ្វើការស្នើសុំអាជ្ញាបណ្ណសិប្បកម្ម ហើយកំណត់ដែនអាជ្ញាបណ្ណក្នុងទីតាំងភូមិ ឬឃុំ/សង្កាត់ដែលអាជីវករអាចធ្វើអាជីវកម្មជីកដីចល័ត ឲ្យបានត្រឹមត្រូវ។ ក្នុងអាជ្ញាបណ្ណសិប្បកម្មនោះ ត្រូវមានការបញ្ជាក់ឲ្យច្បាស់លាស់ថា អាជីវករត្រូវជូនដំណឹងមកមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត យ៉ាងតិច០៣(បី)ថ្ងៃ មុនពេលធ្វើប្រតិបត្តិការជីកយកអាចម៍ដី អំពីទីតាំងជាក់ស្តែងដែលត្រូវជីកយកអាចម៍ដី ទីតាំងដែលត្រូវចាក់បំពេញ ថ្ងៃខែចាប់ផ្តើមនិងថ្ងៃខែបញ្ចប់ការជីកយកអាចម៍ដីនៅទីតាំងស្នើសុំនោះ។ ការប្រកាសបង់សួយសារត្រូវអនុវត្តតាមចំណុច១-២ ខាងលើ។

មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវបង្កលក្ខណៈងាយស្រួលដល់ អាជីវករ ក្រុមហ៊ុនដែលមកធ្វើការប្រកាសសួយសាររ៉ែសំណង់ និងត្រូវចេញលិខិតបញ្ជាក់បង់ប្រាក់ចំណូលសួយសារលើតម្លៃធនធានរ៉ែ ជូនអាជីវករ ក្រុមហ៊ុនភ្លាមៗ ដោយមិនត្រូវឲ្យអាជីវករ ក្រុមហ៊ុនមានការលំបាកក្នុងការរង់ចាំយូរឡើយ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់អស់លោក ក្នុងការអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**